# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀង

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ១១ និង ៣០ នាទី ព្រឹក នៅក្នុងក្រុមហ៊ុន យូជេនេថេក(ខេមបូឌា)ឯ.ក (ទួលគោក) មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត។

នៅក្នុងអង្គប្រជុំនេះ គណៈគ្រប់គ្រងក្រុមហ៊ុនបានជូនដំណឹងដល់ កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្នរបស់ក្រុមហ៊ុន ដោយសារតែជំងឺឆ្លងរាតត្បាតកូវីដ ១៩ បានធ្វើអោយប៉ះពាល់ដល់ ចំណូលក្រុមហ៊ុនទាំងស្រុង។ ដោយហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងអស់រយៈពេលចំនួន៤៧ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករ និយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួល ៤០ភាគរយ ក្នុង១ខែសម្រាប់កម្មករ និយោជិតម្នាក់ៗ។

អង្គប្រជុំបានបញ្ចប់វេលាម៉ោង ១២ គត់ នាថ្ងៃខែឆ្នាំដដែល ដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និងសហការគ្នាយ៉ាងល្អ។

ភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១

**តំណាងកម្មករ និយោជិត**

**នាយកក្រុមហ៊ុន**